## ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

## លក្ខខណ្ឌនៃការផ្ទេរប្រាក់របស់ធនាគារ

សូមអានលក្ខខណ្ឌខាងក្រោមនេះដោយប្រុងប្រយ័ត្ន លក្ខខណ្ឌនេះគឺជាកិច្ចព្រមព្រៀងក្នុងការផ្ទេរប្រាក់ជាមួយធនាគារBIDC។

១. អ្នកស្នើសុំបានអះអាង និងបញ្ជាក់ថារាល់ព័ត៌មាននៅក្នុងពាក្យស្នើសុំផ្ទេរប្រាក់គឺត្រឹមត្រូវ និងពិតប្រាកដមែន។ ធនាគារនឹងមិនទទួលខុសត្រូវរាល់ការយឺតយ៉ាវ ឬកំហុសផ្សេងៗ ដែលអ្នកស្នើសុំបានផ្តល់ព័ត៌មានមិនមានភាពច្បាស់លាស់នៅក្នុងពាក្យស្នើសុំផ្ទេរប្រាក់។

២. ករណីមានការកែប្រែព័ត៌មាន ពន្យារពេលទូទាត់ ឬបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ លោក-លោកស្រី ត្រូវជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរ។

៣. អ្នកស្នើសុំបានផ្តល់សិទ្ធិឲ្យធនាគារធ្វើការដកប្រាក់ចេញពីគណនីរបស់អ្នកស្នើសុំនូវចំនួនប្រាក់ រួមទាំងកម្រៃសេវាផ្សេងៗ។

៤. ធនាគារអាចសម្រេចចិត្តជ្រើសរើស ធនាគារអន្តរការីណាមួយដោយខ្លួនឯងដើម្បីធ្វើប្រតិបត្តិការផ្ទេរប្រាក់។ ធនាគារអន្តរការីអាចដកយកកម្រៃសេវាផ្សេងៗពីចំនួនប្រាក់ដែលផ្ទេរទៅឲ្យអ្នកទទួល ឬកម្រៃសេវានេះនឹងដកយកដោយធនាគារBIDC។ ប្រសិនបើកម្រៃសេវារបស់ធនាគារអន្តរការីត្រូវបានបង់ដោយអ្នកស្នើសុំ ធនាគារBIDC និងធ្វើការដកនូវកម្រៃទាំងនោះពីគណនីអ្នកស្នើសុំ។

៥. ធនាគារBIDC មានសិទ្ធិធ្វើការកែប្រែថ្លៃសេវាកម្ម និងកម្រៃ ក៏ដូចជាលក្ខខណ្ឌទាំងអស់គ្រប់ពេលវេលាដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុន។

៦. ធនាគារBIDC អាចផ្តល់ព័ត៌មាននៃការផ្ទេរប្រាក់ទៅឲ្យភាគីទីបី ដែលកំណត់ដោយច្បាប់ព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលការសម្រេចពីតុលាការស៊ើបអង្កេត និងបទបញ្ជារបស់ធនាគារជាតិ។

៧. អ្នកស្នើសុំត្រូវធានាថា រាល់ប្រតិបត្តិការបានអនុលោមយ៉ាងតឹងរឹង ទៅតាមបទបញ្ញត្តិនិងច្បាប់បច្ចុប្បន្នភាព របស់ព្រះរាជាណាចក្រកម្ពុជា និងធនាគារBIDC។ លោក-លោកស្រីត្រូវទទួលខុសត្រូវទាំងស្រុងចំពោះច្បាប់ជាតិ និងអន្តរជាតិលើប្រតិបត្តិការផ្ទេរប្រាក់នេះ ក្នុងនាមខ្លួនឯងផ្ទាល់ និងសាច់ញាតិ ឬប្រតិបត្តិការទូទាត់ក្រោមកិច្ចសន្យា។

៨. អ្នកស្នើសុំផ្តល់សិទ្ធិឲ្យធនាគារធ្វើការពន្យា ឬបញ្ឈប់ ឬលុបចោលនូវការផ្ទេរប្រាក់ ប្រសិនបើធនាគារBIDC ឬធនាគារអន្តរការីបានរកឃើញថាការផ្ទេរប្រាក់មិនគោរពច្បាប់ជាតិ ឬអន្តរជាតិ។

៩. អ្នកស្នើសុំទទួលរ៉ាប់រងថា ការផ្ទេរប្រាក់គឺមិនមានទាក់ទងនឹងសកម្មភាពមិនស្របច្បាប់ ការសំអាតប្រាក់ ឬជាសកម្មភាពហិរញ្ញប្បទានភេរវកម្ម។

១០. អ្នកស្នើសុំយល់ព្រមផ្តល់ឯកសារបន្ថែម ឬព័ត៌មានដែលជាប់ពាក់ព័ន្ធទៅនឹងប្រតិបត្តិការ របស់លោក-លោកស្រី ក្នុងករណីដែលអាជ្ញាធរប្រទេសកម្ពុជាស្នើសុំ។